ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៦ ......សហវ.......

ថ្ងៃសុក្រ ៣ រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១

## សេចក្ដីជូនដំណឹង
## ស្ដីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជាមន្ត្រីរាជការ
## ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់មន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន ឱ្យបានជ្រាបថា ក្រសួងនឹងរៀបចំការប្រឡងជ្រើសរើសបេក្ខជនជាមន្ត្រីរាជការ ទាំងពីរភេទ ចំនួន ៥០ នាក់ (**ប្រភេទក្របខណ្ឌ “ក” ចំនួន ៣០ រូប និង “ខ” ចំនួន ២០ រូប**) ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមតារាងបែងចែកក្របខណ្ឌ និងលក្ខខណ្ឌកំណត់ដូចខាងក្រោម÷

| ល.រ | ជំនាញបច្ចេកទេស | ចំនួន | ចំនួនតាមប្រភេទក្របខណ្ឌ | |
|---|---|---|---|---|
| | | | ក | ខ |
| ១ | បច្ចេកវិទ្យាព័ត៌មាន | ១៥ | ១០ | ៥ |
| ២ | ច្បាប់ | ៣ | ៣ | ០ |
| ៣ | ធនធានមនុស្ស | ៧ | ២ | ៥ |
| ៤ | ពាណិជ្ជកម្មអន្តរជាតិ | ៥ | ៥ | ០ |
| ៥ | វិភាគសេដ្ឋកិច្ច | ៣ | ៣ | ០ |
| ៦ | សុវត្ថិភាពម្ហូបអាហារ, គុណភាពទំនិញ, ភូតគាមអនាម័យ | ១០ | ៥ | ៥ |
| ៧ | ជំនាញមន្ទីរពិសោធន៍ | ២ | ២ | ០ |
| ៨ | គណនេយ្យករជំនាញ | ៥ | ០ | ៥ |
| **សរុប** | | **៥០** | **៣០** | **២០** |

**១.លក្ខខណ្ឌនៃការជ្រើសរើស÷**

**-សញ្ញាបត្រជំនាញដែលតម្រូវសម្រាប់ការជ្រើសរើស**

| ល.រ | ជំនាញបច្ចេកទេស | សញ្ញាបត្រជំនាញ | បទពិសោធន៍ការងារ |
|---|---|---|---|
| ១ | បច្ចេកវិទ្យាព័ត៌មាន | បច្ចេកវិទ្យាព័ត៌មាន | Network and Infrastructure Specialist, Software Developer, Multimedia Specialist, Database Administrator, Data Analyst |
| ២ | ច្បាប់ | នីតិសាស្ត្រ, រដ្ឋបាលសាធារណៈ | រៀបចំលិខិតគតិយុត្ត ឬបណ្ដឹង,ការងារផ្នែករដ្ឋបាល-សាធារណៈ |

| ល.រ | ជំនាញបច្ចេកទេស | សញ្ញាបត្រជំនាញ | បទពិសោធន៍ការងារ |
|---|---|---|---|
| ៣ | ធនធានមនុស្ស | ធនធានមនុស្ស ឬប្រហាក់ប្រហែល | គ្រប់គ្រងបុគ្គលិក, វាយតម្លៃបុគ្គលិក, គ្រប់គ្រងវគ្គ-បណ្តុះបណ្តាល, រៀបចំផែនការអភិវឌ្ឍធនធានមនុស្ស |
| ៤ | ពាណិជ្ជកម្មអន្តរជាតិ | គ្រប់គ្រងពាណិជ្ជកម្ម, សេដ្ឋកិច្ច ឬប្រហាក់ប្រហែល | ការនាំចេញនាំចូល, គោលនយោបាយពាណិជ្ជកម្ម, អង្គការពាណិជ្ជកម្មពិភពលោក, តំបន់ពាណិជ្ជកម្មសេរី |
| ៥ | វិភាគសេដ្ឋកិច្ច | | វិភាគនិងព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច, គោលនយោបាយ-សារពើពន្ធ, ស្ថិតិ |
| ៦ | សុវត្ថិភាពម្ហូបអាហារ, គុណភាពទំនិញ, ភូតតាមអនាម័យ | គីមីសាស្ត្រ, វិទ្យាសាស្ត្រម្ហូប-អាហារ, វិទ្យាសាស្ត្រសុខាភិបាល, វិទ្យាសាស្ត្រកសិកម្ម, រុក្ខកម្ម, ជលផល និងសត្វ ឬប្រហាក់ប្រហែល | ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពទំនិញ, ត្រួតពិនិត្យទំនិញក្លែងក្លាយ, ត្រួតពិនិត្យអនាម័យនិងភូតតាមអនាម័យ |
| ៧ | ជំនាញមន្ទីរពិសោធន៍ | | សេវាកម្មពិសោធន៍, វិភាគសំណាកទំនិញ |
| ៨ | គណនេយ្យករជំនាញ | គណនេយ្យ, ហិរញ្ញវត្ថុ ឬធនាគារ | រដ្ឋទេយ្យករចំណូល, គណនេយ្យករ, សវនកម្ម, វិភាគហិរញ្ញវត្ថុ |

**-ក្របខណ្ឌ "ក"**

- **បេក្ខជនជាមន្ត្រីរាជការ÷** ត្រូវមានអតីតភាពយ៉ាងតិច ៣ ឆ្នាំ បន្ទាប់ពីការតាំងស៊ប់ក្នុងក្របខណ្ឌ ឬតាមការកំណត់ដោយឡែកណាមួយរបស់ក្រសួង-ស្ថាប័នសាមីរបស់បេក្ខជន។
- **កម្រិតបណ្តុះបណ្តាល÷** សញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រមានតម្លៃសមមូលឡើងទៅ

**-ក្របខណ្ឌ "ខ"**

- **បេក្ខជនជាមន្ត្រីរាជការ÷** ត្រូវមានអតីតភាពយ៉ាងតិច ៣ ឆ្នាំ បន្ទាប់ពីការតាំងស៊ប់ក្នុងក្របខណ្ឌ ឬតាមការកំណត់ដោយឡែកណាមួយរបស់ក្រសួង-ស្ថាប័នសាមីរបស់បេក្ខជន។
- **កម្រិតបណ្តុះបណ្តាល÷** សញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រមានតម្លៃសមមូលឡើងទៅ

**២.វិញ្ញាសាប្រឡង÷**

វិញ្ញាសាប្រឡង ជាវិញ្ញាសាសរសេររួមមាន÷

វិញ្ញាសាទី១ ÷ ចំណេះដឹងទូទៅ មេគុណ ១

វិញ្ញាសាទី២ ÷ ភាសាបរទេស មេគុណ ១

វិញ្ញាសាទី៣ ÷ ជំនាញបច្ចេកទេស មេគុណ ២

**៣.កាតព្វកិច្ចបំពេញការងារ÷**

បេក្ខជន ដែលត្រូវបានជ្រើសរើសចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញការងារយ៉ាងតិចចំនួន ០៣ ឆ្នាំ នៅកន្លែងការងារដែលសាមីជនបានជ្រើសរើសនៅពេលប្រឡង ទើបមានសិទ្ធិអាចសុំផ្លាស់ប្តូរកន្លែងការងារ។

**៤.ការដាក់ពាក្យសុំចូលប្រឡង÷**

បេក្ខជន ត្រូវបំពេញពាក្យសុំចូលរួមប្រឡងតាមរយៈប្រព័ន្ធ Online ដែលអាចរកបាននៅគេហទំព័រនាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ www.pd.mef.gov.kh គេហទំព័រអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា www.customs.gov.kh ឬគេហទំព័រវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ www.efi.mef.gov.kh និងត្រូវដាក់ពាក្យនៅនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន កសហវ., អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀងរាល់ម៉ោងធ្វើការ (០៨:០០ ដល់ ១១:៣០ នាទីព្រឹក និង ១៤:០០ ដល់ ១៧:៣០ នាទីរសៀល) ***ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។***

ចំពោះកាលបរិច្ឆេទប្រឡង មណ្ឌលប្រឡង និងបញ្ជីរាយនាមបេក្ខជន គណៈកម្មការរៀបចំការប្រឡង នឹងបិតផ្សាយនៅនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ បេក្ខជនអាចទទួលព័ត៌មានតាមគេហទំព័រខាងលើ។

**កំណត់ចំណាំ÷

*បេក្ខជនដែលមានបំណងដាក់ពាក្យចូលរួមការប្រកួតប្រជែងត្រូវមានលិខិតបញ្ជាក់រដ្ឋបាល ដែលបញ្ជាក់ដោយប្រធានអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិក ឬប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ និងត្រូវមានកាយសម្បទាគ្រប់គ្រាន់។*

*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមទូរស័ព្ទ÷*

| នាយកដ្ឋានបុគ្គលិក | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
|---|---|---|
| -០១១ ៧១៤ ៦១៧ | -០១២ ២៤៤ ៤៣៤ | -០១២ ៥៥៥ ២១៤ |
| -០១០ ២៣៨ ៤៥៦ | -០១២ ៧០១ ២៣៦ | -០១៦ ៧២១ ០៩៦ |
| -០១៦ ៩៣៣ ១៧១ | -០១២ ៥២៥ ៥៨៨ | -០៨៩ ៨៦០ ៦៩៦ |

**រដ្ឋលេខាធិការ និងជា**

**ប្រធានគណៈកម្មការប្រឡង**

បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

**កន្លែងទទួល÷**

- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- អគ្គលេខាធិការដ្ឋាន កសហវ.
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីសហការចាត់ចែងផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំចុះឈ្មោះប្រឡងចូលបម្រើការងារនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ....................................... ជាអក្សរឡាតាំង.................................... សញ្ជាតិ.......... ភេទ...........

កើតថ្ងៃទី........... ខែ.......... ឆ្នាំ........... នៅភូមិ................................. ឃុំ/ សង្កាត់.....................................................

ខណ្ឌ/ ស្រុក/ ក្រុង........................................... រាជធានី- ខេត្ត.....................................................................................។

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ខ្ញុំបាទ/ នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាជ្រាបថា បច្ចុប្បន្ន ខ្ញុំបាទ/ នាងខ្ញុំ ជាមន្ត្រីរាជការ កំពុងបម្រើការងារនៅ (*ក្រសួង- ស្ថាប័ន*)...........................................................................................................

**តួនាទី**........................................................ ស្ថិតក្នុង**ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់**.....................។

សូមភ្ជាប់មកជាមួយនូវ÷

| | | |
|---|---|---|
| ១. លិខិតបញ្ជាក់ស្ថានភាពរដ្ឋបាល | ចំនួន | ១ច្បាប់ |
| ២. សលាកបត្រឯកត្តជន | ចំនួន | ១ច្បាប់ |
| ៣. ច្បាប់ចម្លងសញ្ញាបត្រដោយមានបញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច | ចំនួន | ១ច្បាប់ |
| ៤. អត្តសញ្ញាណប័ណ្ណដោយមានបញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច | ចំនួន | ១ច្បាប់ |

អាស្រ័យហេតុនេះ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាពិនិត្យលទ្ធភាពចុះឈ្មោះ ខ្ញុំបាទ/ នាងខ្ញុំ ក្នុងបញ្ជីបេក្ខជនប្រឡងប្រជែងចូលបម្រើការងារអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** មេត្តាទទួលនូវការគោរពកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

ថ្ងៃ.......................... ខែ............. ឆ្នាំឆ្លូវ ត្រីស័ក ព. ស. ២៥៦៥

................. ថ្ងៃទី.......... ខែ............ ឆ្នាំ២០២១

**ហត្ថលេខា និងឈ្មោះ**

៦៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង-ស្ថាប័ន:....................................**
**អង្គភាព:..............................................**

រូបថត ៤x៦

(មិនលើសពី ៦ខែ)

**<u>លិខិតបញ្ជាក់ស្ថានភាពរដ្ឋបាល</u>**

សូមបញ្ជាក់ថាលោក/ លោកស្រី/ កញ្ញា ឈ្មោះ......................................... អក្សរឡាតាំង ........................................
ភេទ .......... សញ្ជាតិ............... ថ្ងៃខែឆ្នាំកំណើត .................................. តួនាទីបច្ចុប្បន្ន÷....................................
បម្រើការងារនៅក្រសួង/ ស្ថាប័ន÷ ..........................................................................................................
ប្រភេទក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ចុងក្រោយ÷......................ថ្ងៃខែឆ្នាំចូលបម្រើការងាររដ្ឋដំបូង÷ .........................
ថ្ងៃខែឆ្នាំតាំងស៊ប់÷.......................... រយៈពេលបម្រើការងារ............................ ។

ខ្ញុំសូមធានាអះអាងព័ត៌មានខាងលើនេះ ពិតជាត្រឹមត្រូវប្រាកដមែន។

**សូមភ្ជាប់មកជាមួយនូវឯកសារតាំងស៊ប់របស់សាមីមន្ត្រី*

ថ្ងៃ........................ ខែ.......... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
...................ថ្ងៃទី..........ខែ.............ឆ្នាំ២០២១
**ប្រធានអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិក/**
**ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់**